# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជារំលឹកលោកបូជាចារ្យប៊ូយៀបនៅផ្លូវត្រី
# ថ្ងៃទី១២ មីនា ២០១៧

អត្ថបទទី១៖ កណ ១២,១-៤ក
អត្ថបទទី២៖ ២ធម ១,៨ខ-១០
ដំណឹងល្អ៖ មថ ១៧,១-៩

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយដ៏ពិសេស ដោយសារលោកឪពុកប៊ូយៀបដូចជាប្រមូលយើងយ៉ាងច្រើនពីមួយឆ្នាំទៅមួយឆ្នាំច្រើនទៅៗ កន្លែងយើងក៏ធំទូលាយដើម្បីទទួលបងប្អូន។ នេះយើងអរគុណដល់លោកឪពុលវីរៈជ័យ បងប្រុសបងស្រី បងប្អូនគ្រីស្តបរិស័ទដែលជួយថែរក្សាកន្លែងនេះ ឲ្យយើងដឹងថានៅថ្ងៃទី១២ខែមីនាយើងអាចមកបានច្រើន ដើម្បីអធិដ្ឋាន និងជួបជាមួយព្រះជាម្ចាស់។ ថ្ងៃនេះខ្ញុំសូមអរគុណលោកឪពុកប៊ូយៀប ដែលបានបងប្អូនយ៉ាងច្រើនដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ព្រះបន្ទូលថ្ងៃនេះជាព្រហបន្ទូលដែលណែនាំយើងត្រូវតែភ្ញាក់ ក្នុងអត្ថបទទីមួយ ព្រះជាម្ចាស់បានជ្រើសរើសលោកអាប្រាហាំ "**យើងនឹងធ្វើឲ្យអាប្រាហាំមានឈ្មោះល្បី**"។ ក្នុងគម្ពីរដំណឹងល្អព្រះយេស៊ូបានជ្រើសរើសលោកសិលា លោកយ៉ាកុប និងលោកយ៉ូហាន ដើម្បីមានបទពិសោធន៍ពិសេសគឺមើលឋានៈព្រះយេស៊ូជាព្រះបុត្រារបស់ព្រះជាម្ចាស់តែម្តង។ ក្នុងអត្ថបទីពីរ យើងបានស្តាប់ព្រះជាម្ចាស់បានជ្រើសរើសយើង ឲ្យយើងធ្វើជាប្រជារាស្ត្រដ៏វិសុទ្ធរបស់ព្រះអង្គ។ ព្រះជាម្ចាស់បានជ្រើសរើសលោកឪពុកប៊ូយៀប ដែលអាចទៅជាសន្តម្នាក់ដែលបំភ្លឺជីវិតរបស់យើងតាមរបៀបដែលគាត់បានបម្រើ នឹងស្រឡាញ់ព្រះសហគមន៍របស់ព្រះជាម្ចាស់។ ខ្ញុំជឿថា ព្រះជាម្ចាស់បានជ្រើសរើសយើងទាំងអស់គ្នានៅទីនេះ ដើម្បីទទួលជីវិតពីព្រះជាម្ចាស់ផ្ទាល់។

ភូមិភាគភ្នំពេញមិនធំប៉ុន្មានទេ ប៉ុន្តែជាកន្លែងមួយដែលព្រះជាម្ចាស់បានជ្រើសរើសដើម្បីឲ្យដីក្នុងភូមិភាគភ្នំពេញមានសាក្សីនៃជំនឿយ៉ាងច្រើន។ មានលោកប៊ូយៀបទទូលខុសត្រូវនៅផ្លូវត្រីនេះក្នុងឆ្នាំ១៩២៤ លោកឆ្មារសាឡាស់ ដែលសុខចិត្តលះបង់ចោលបូជាជីវិតសម្រាប់ព្រះសហគមន៍ និងមានព្រះនាងម៉ារីនៅអរីយក្សត្រ។ ពិតមែនព្រះជាម្ចាស់ស្រឡាញ់យើង ព្រះជាម្ចាស់ចង់ឲ្យយើងមានជីវិតថ្មីនឹងពិសេសអស្ចារ្យ។ **ព្រះជាម្ចាស់ជ្រើសរើសយើងដើម្បីអ្វី?** យើងស្តាប់នៅក្នុងគម្ពីរដំណឹងល្អ **អ្នកនេះជាបុត្រដ៏ជាទីស្រឡាញ់របស់យើង យើងគាប់ចិត្តនឹងព្រះអង្គណាស់ ចូរស្តាប់ព្រះអង្គចុះ**។ ព្រះជាម្ចាស់បានជ្រើសរើស

យើងឲ្យយើងស្ដាប់ព្រះបន្ទូលរបស់ព្រះអង្គ លោកអាប្រាហាំស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ គាត់សុខចិត្តចេញពីទឹកដីរបស់គាត់ ដើម្បីទទួលស្គាល់មានព្រះជាម្ចាស់តែមួយគត់ដែលជាព្រះដ៏វិសុទ្ធ។ យើងទាំងអស់គ្នាជាកូនចៅរបស់លោកតាអាប្រាហាំ គាត់បាផ្លែច្រើនរាប់ជំនាន់មកហើយ។ ព្រះនាងម៉ារីបានស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះនាងសុខចិត្តធ្វើជាមាតារបស់ព្រះយេស៊ូតែម្ដង ដោយសារព្រះនាងម៉ារីសុខចិត្តស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ព្រះយេស៊ូបានយាងមកក្នុងពិភពលោកនេះ ដើម្បីប្រទានជីវិតឲ្យមនុស្សលោកយើង។ គ្រីស្តទូតទាំង១២គេបានស្ដាប់ព្រះបន្ទូលរបស់ព្រះយេស៊ូ សូមទៅទូទាំងពិភពលោកទាំងមូលរហូតដល់តំបន់ដាច់ស្រយ៉ាលនៃផែនដី ដើម្បីធ្វើអគ្គសញ្ញាជ្រមុជទឹកដោយនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ គេបានធ្វើជាមូលហេតុសព្វថ្ងៃយើងមានព្រះសហគមន៍កាតូលិកនៅគ្រប់ទីកន្លែងក្នុងពិភពលោកទាំងមូល។ លោកប៉ូយៀប ក៏ដូចគ្នាដែរគាត់បានស្ដាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ និងសុខចិត្តធ្វើជាបូជាចារ្យដើម្បីបម្រើព្រះសហគមន៍អស់ពីសមត្ថភាពរហូតដល់គាត់ស្លាប់។ ក្នុងរដូវ៤០ថ្ងៃនេះ យើងត្រូវការសួរខ្លួនឯងថា **តើព្រះជាម្ចាស់ជ្រើសរើសខ្ញុំដើម្បីធ្វើអ្វីខ្លះ?** ព្រះជាម្ចាស់ជ្រើសខ្ញុំ ដោយខ្ញុំមិនមែនលោកអាប្រាហាំ ខ្ញុំមិនមែនលោកសិលា ខ្ញុំមិនមែនម៉ារី ខ្ញុំមិនមែនលោកប៉ូយៀប ប៉ុន្តែព្រះជាម្ចាស់បានជ្រើសរើសខ្ញុំដើម្បីឲ្យខ្ញុំបម្រើជីវិត បម្រើព្រះសហគមន៍ និងទៅជាសាវ័ករបស់ព្រះយេស៊ូដែរ។ តាមពិតព្រះជាម្ចាស់បានជ្រើសរើសយើង ឲ្យយើងធ្វើជាមនុស្សដ៏វិសុទ្ធដូចយើងបានស្ដាប់ក្នុងអត្ថបទទីពីរ ដើម្បីឲ្យយើងទៅជាអ្នកដ៏វិសុទ្ធ ពីថ្ងៃយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានធ្វើដំណើរជាមួយព្រះយេស៊ូ ដើម្បីរស់នៅតាមរបៀបព្រះយេស៊ូតែម្ដង។ យើងអធិដ្ឋានដើម្បីឲ្យយើងរកស៊ីបានច្រើន ប៉ុន្តែប្រយ័ត្នព្រោះយើងមិនដែលនឹកឃើញអត្ថបទដែលសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ ផ្ញើរជូនគ្រីស្តបរិស័ទសម្រាប់រដូវ៤០ថ្ងៃ គឺអត្ថបទស្ដីអំពីលោកឡាសានិងអ្នកមាន។ អ្នកមានចង់មានច្រើនប៉ុន្តែគាត់ភ្លេចបើកទ្វារដើម្បីមើលលោកឡាសា ដែលនៅក្បែរទ្វារផ្ទះគាត់សុំទាន សុំម្ហូបអាហារដែលសល់ពីតុរបស់គាត់រៀងរាល់ថ្ងៃ។ គាត់ចង់បានច្រើន ដើម្បីមោទនភាព កិត្តិយស និងភាពអត្មានិយមរបស់គាត់ផ្ទាល់ ប៉ុន្តែគាត់គ្មានចិត្តដើម្បីមើលអ្នកដែលកំពុងខ្វះខាត ដែលកំពុងពិបាក ដែលកំពុងអស់សង្ឃឹម គាត់បិទភ្នែក បិទត្រចៀក បិទបេះដូងរបស់គាត់អស់ហើយ គឺគ្មានចិត្តអាណិតមេត្តា។ ហេតុនេះហើយព្រះសហគមន៍ មិនដែលហាមយើងឲ្យយើងរកស៊ីទេ ប៉ុន្តែព្រះសហគមន៍ណែនាំឲ្យយើងចេះប្រើទ្រព្យសម្បត្តិរបស់យើង ដើម្បីចិញ្ចឹមជីវិតក្រុមគ្រួសារយើង

និងចេះបើកចិត្តគំនិតសម្រាប់ចែករំលែកដល់អ្នកដទៃដែរ នេះជាជីវិតរបស់យើងជាគ្រីស្ទបរិស័ទ ជាសាវ័ករបស់ព្រះយេស៊ូ។ ពីដើមក្រុមគ្រីស្ទបរិស័ទ ជាមួយក្រុមគ្រីស្ទទូតជួបជុំគ្នាដើម្បីអធិដ្ឋាន ទទួលការអប់រំពីក្រុមគ្រីស្ទទូត និងចែករំលែកដល់អ្នកក្រីក្រ។ រហូតដល់សព្វថ្ងៃដ៏ដូចគ្នាដែរ ព្រះសហគមន៍ភូមិភាគភ្នំពេញនៅមានដំណើរការបាន ដោយសារ៩០%នៃលុយដែលយើងមានមកពីគ្រីស្ទបរិស័ទទូទាំងពិភពលោកទាំងមូលដែលជួយចែករំលែកជាមួយយើង។ នេះជាជីវិតរបស់យើងជាគ្រីស្ទបរិស័ទ ធ្វើយ៉ាងណាដើម្បីឲ្យយើងចេះបើកចិត្តគំនិត ឲ្យចេះមើល ចេះស្តាប់បងប្អូនឯទៀតៗដែលកំពុងមានសេចក្តីត្រូវការខាងផ្លូវការខាងផ្លូវចិត្ត ដោយថែរក្សាចិត្តអាណិតមេត្តាជានិច្ច។

កំពូលនៃជីវិតរបស់យើងជាគ្រីស្ទបរិស័ទ មិនមែនតែចែករំលែកទ្រព្យសម្បត្តិរបស់យើងតិចតួច ប៉ុន្តែចេះចែករំលែកសេចក្តីស្រឡាញ់ដូចលោកឆ្មារសាឡាស់ និងលោកប៉ូយៀប បានបូជាជីវិត ដូចព្រះយេស៊ូនៅលើឈើឆ្កាង។ ថ្ងៃនេះខ្ញុំសួរសុខទុក្ខ និងផ្ញើការសួរសុខទុក្ខដល់បងប្អូនទាំងអស់ពីសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ដែលក្រុមលោកអភិបាលឡាវកម្ពុជាបានជួបមួយខែមុន សម្តេចប៉ាបបានមានប្រសាសន៍ដល់យើងទាំងអស់ថា ព្រះសហគមន៍នៅប្រទេសកម្ពុជាជាព្រះសហគមន៍តូច ប៉ុន្តែជាព្រះសហគមន៍ដែលណែនាំឲ្យព្រះសហគមន៍សកលមានកម្លាំង ដោយសារព្រះសហគមន៍តូចនេះសុខចិត្តបូជាជីវិត និងលះបង់ចោលច្រើន ដើម្បីផលប្រយោជន៍បងប្អូនឯទៀតៗ។ យើងមិនចង់បូជាជីវិតដូចព្រះយេស៊ូនៅថ្ងៃស្អែក ប៉ុន្តែយើងដឹងថានេះជាជីវិតរបស់យើងធ្វើយ៉ាងណាដើម្បីចែករំលែកជាមួយបងប្អូនឯទៀតៗជានិច្ច។ ខ្ញុំសូមអរគុណដល់បងប្អូនដែលបានជួយក្នុងការកសាងនៅទីនេះ ដែលជាស្នាដៃមួយដ៏អស្ចារ្យ ប៉ុន្តែកុំឲ្យយើងភ្លេចយើងអាចកសាងអាគារប៉ុន្មានក៏បាន អ្វីដែលសំខាន់ឲ្យយើងមានចិត្តអាណិតមេត្តាជានិច្ចសម្រាប់អ្នកតូចតាច សម្រាប់កូនក្មេងដែលគ្មានសេចក្តីសង្ឃឹម សម្រាប់អ្នកដែលគ្មានផ្លូវដើរនៅក្នុងជីវិត។ ម្សិលមិញខ្ញុំបានទទួលសំបុត្រពីកាឌីណាល់ ហ្វីលូនី ដែលបន្តពីសម្តេចប៉ាប ទទួលខុសត្រូវលើព្រះសហគមន៍យើង គាត់បានសរសេរថា **លោកអភិបាលសុំជួយដើម្បីឲ្យយើងយល់ថា ការចែករំលែកធម៌មេត្តាករុណាដល់កំពូល គឺជាសាក្សីអំពីព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងជីវិតប្រចាំ ដើម្បីឲ្យមនុស្សយ៉ាងច្រើនស្គាល់ព្រះយេស៊ូ។**

សម្រាប់រដូវ៤០ថ្ងៃនេះ ឲ្យយើងបើកត្រចៀកដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងឲ្យព្រះបន្ទូលដែលយើងស្តាប់ហើយ ឲ្យយើងយកចិត្តទុកដាក់អនុវត្តជាក់ស្តែងនៅក្នុងជីវិតរបស់យើងប្រចាំថ្ងៃ។ សូមបងប្អូនទាំងអស់ជ្រើសរើសព្រះបន្ទូលមួយ និងខិតខំអនុវត្តក្នុង៤០ថ្ងៃនេះដើម្បីរៀបចំចិត្តគំនិតធ្វើជាអង្គតែមួយ ផ្លូវតែមួយជាមួយព្រះយេស៊ូ។ សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះជាម្ចាស់ប្រទានពរដល់បងប្អូនទាំងអស់ដើម្បីមានជំនឿរឹងមាំ មានសេចក្តីស្រឡាញ់ដ៏ពេញលក្ខណៈ ដើម្បីធ្វើជាសាវ័ករបស់ព្រះយេស៊ូដូចគំរូរបស់យើងថ្ងៃនេះគឺលោកអាប្រាហាំ លោកសិលា លោកយ៉ូហាន លោកយ៉ាងកុប និងលោកប៊ួយៀប។ អាម៉ែន។